# សេចក្តីថ្លែងអំណរគុណ

សៀវភៅ "**បច្ចេកទេសដាំឈើសំរាប់កសិករ**" នេះជាសមិទ្ធិផលថ្មីមួយនៃការងារផ្សព្វផ្សាយព្រៃឈើរបស់នាយកដ្ឋានរុក្ខា-ប្រមាញ់នៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ។ ជោគជ័យក្នុងដំណើរការរៀបចំសៀវភៅនេះ គឺអាស្រ័យទាំងស្រុងទៅលើកិច្ចសហប្រតិបត្តិការ និង ការចូលរួមរបស់ បុគ្គល និងស្ថាប័នជាច្រើន។ ដើម្បីកត់ត្រាទុកនូវវិភាគទានដ៏មានតម្លៃទាំងនេះនាយកដ្ឋានរុក្ខា-ប្រមាញ់ សូមថ្លែងអំណរគុណចំពោះក្រុមការងាររៀបចំសៀវភៅ រួមមានលោក នុព សុធា លោក យៀង អៀងតិច លោក ប៉ុល ចាន់ថា លោក សៀង ស៊ុន លោក អ៊ី ឈាងម៉េង លោក សូ ធា លោក ឡុង ប៊ុង និង លោក ហុង គឹមហ៊ាន ដែលបានខិតខំស្រាវជ្រាវ ចងក្រង និង រចនារូបភាព ធ្វើឱ្យសៀវភៅនេះបានលេចជារូបរាងឡើងប្រកបដោយអត្ថប្រយោជន៏សំរាប់វិស័យព្រៃឈើ ក៏ដូចវិភាគទានចូលរួមកាត់បន្ថយភាពក្រីក្រនៅជនបទកម្ពុជា។

សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះលោក Jürgen Fichtenau ជំនាញការផ្នែកផ្សព្វផ្សាយ និង សហគមន៏ព្រៃឈើនៃគំរោងសហប្រតិបត្តិការវិស័យព្រៃឈើកម្ពុជា-អាល្លឺម៉ង់ លោក Arvid Sloth ទីប្រឹក្សានៃគំរោង គ្រាប់ពូជឈើកម្ពុជា និង លោក Minoru Arai ជំនាញការបណ្តុះបណ្តាលនៃគំរោងពង្រឹងសមត្ថភាពលើវិស័យព្រៃឈើ ដែលបានចូលរួមផ្តល់ការពីគ្រោះយោបល់ដ៏មានតម្លៃនានាក្នុងដំណើរការរៀបចំសៀវភៅនេះ។

សូមថ្លែងអំណរគុណ ចំពោះ លោក លិ វុឌ្ឍី លោក វន មុនិន្ទ លោក ឌី សុភី និង លោក ឃន សារ៉េត ដែលបានជួយផ្តល់នូវចំណេះដឹងពីបទពិសោធន៏ និងឯកសារមួយចំនួនដល់ការចងក្រង។

សូមសំដែលនូវកតញ្ញូតាធមិ និង ដឹងគុណយ៉ាងជ្រាលជ្រៅចំពោះអង្គការ GTZ, DANIDA JICA, PRASAC II Kompong Speu ដែលបានផ្តល់ការឧបត្ថម្ភដល់ការចងក្រង និង បោះពុម្ពសៀវនៅនេះ ។

នាយកដ្ឋានរុក្ខា-ប្រមាញ់ក៏សូមសំដែងអំណរគុណជាពិសេសចំពោះថ្នាក់ដឹកនាំនាយកដ្ឋានប្រធាន អនុប្រធាន អង្គភាពក្រោមឱវាទ និង មន្ត្រីរាជការនៃនាយកដ្ឋានរុក្ខា-ប្រមាញ់ ដែលបានផ្តល់ភាពងាយស្រួល ជំរុញលើកទឹកចិត្ត ដឹកនាំអង្គប្រជុំពិគ្រោះយោបល់ និង ផ្តល់គំនិតកែលំអលើសេចក្តីព្រាងសៀវភៅបច្ចេកទេសដាំឈើសំរាប់កសិករនេះ រហូតដល់សៀវភៅនេះត្រូវបានរៀបចំចប់សព្វគ្រប់ និង បោះពុម្ពផ្សព្វផ្សាយនាពេលនេះ ។